*បណ្ណព័ត៌មានអំពីជំងឺឆ្លង*

# ជំងឺសាទ្បាទែន

*សាទ្បាទែនគឺជាជំងឺឆ្លងមួយដែលបង្កដោយវីរុស ហើយដែលកើតមានជាចំបងចំពោះកុមារមានអាយុទៅសាលារៀន។ ការចាក់ថ្នាំបង្ការរោគ **MMR** បង្ការជំងឺនេះ។ អ្នកកើតសាទ្បាទែនគួរចៀសវាងអ្នកដទៃរយៈពេលប្រាំបួនថ្ងៃ ក្រោយពីចេញការហើមក្រពេញទឹកមាត់។*

## តើសាទ្បាទែនគឺជាជំងឺអ្វី?

សាទ្បាទែនគឺជាជំងឺឆ្លងមួយដែលបណ្តាលដោយវីរុសសាទ្បាទែន។ នៅពេលកន្លងមក ជំងឺសាទ្បាទែនមានភាពទូទៅណាស់នៅក្នុងចំណោមកុមារ។ ដោយសារតែការចាក់ថ្នាំបង្ការរោគ ឥឡូវនេះជំងឺនេះកំរកើតមានណាស់នៅក្នុងប្រទេសអូស្ត្រាលី។

## តើជំងឺនេះមានរោគសញ្ញាអ្វីខ្លះ?

- រោគសញ្ញាទូទៅនៃសាទ្បាទែនគឺគ្រុនក្តៅ មិនឃ្លានចំណីអាហារ អស់កម្លាំង និងឈឺក្បាល បន្ទាប់មកទៀតគឺការហើម និងការងាយឈឺចាប់នៃក្រពេញទឹកមាត់។ ក្រពេញមួយក្នុងចំណោមក្រពេញទឹកមាត់ប៉ារ៉ូទីដទាំងពីរ (ដែលស្ថិតនៅក្នុងថ្ពាល់នៅក្បែរគល់ថ្គាមខាងក្រោមត្រចៀក) ទទួលរងផលប៉ះពាល់ញឹកញយបំផុត។
- អ្នកកើតជំងឺនេះចំនួនប្រហែលមួយភាគបី មិនបង្ហាញរោគសញ្ញាណាមួយទាល់តែសោះ។
- ជាធម្មតា សាទ្បាទែនគឺជាជំងឺរឹតតែធ្ងន់ធ្ងរឡើងចំពោះអ្នកដែលកើតជំងឺនេះក្រោយពីឈានចូលវ័យអាចបង្កើតកូនបាន។
- ផលវិបាកទាំងឡាយដោយសារសាទ្បាទែនកំរកើតមានណាស់ ហើយអាចមានរួមទាំងការរលាកខួរក្បាល រលាកភ្នាសខួរក្បាលនិងខួរឆ្អឹងខ្នង(រលាកស្រោមខួរ) រលាកពងស្វាស រលាកអូវែរ រលាកសុដន់ ការរលូតកូន និងការបាត់បង់សោតវិញ្ញាណ (ភាពអាចស្តាប់បាន)។ ការធ្វើឲ្យបុរសមិនអាចមានកូនបានកំរកើតមានណាស់។

## តើជំងឺនេះឆ្លងតាមរបៀបណា?

- សាទ្បាទែនឆ្លងនៅពេលដែលមនុស្សម្នាក់ដកដង្ហើមស្រូបចូលនូវវីរុសសាទ្បាទែន ដែលក្អកឬកណ្តាស់ចេញទៅក្នុងខ្យល់អាកាស ដោយអ្នកកើតសាទ្បាទែន។ វីរុសសាទ្បាទែនក៏អាចឆ្លងពីមនុស្សម្នាក់ទៅកាន់ម្នាក់ទៀតតាមរយៈការប៉ះពាល់ដោយផ្ទាល់នឹងទឹកមាត់ដែលមានមេរោគផងដែរ។
- អ្នកកើតសាទ្បាទែនអាចចម្លងជំងឺនេះដល់ទៅប្រាំពីរថ្ងៃនៅមុនពេលចាប់ផ្តើមហើមក្រពេញទឹកមាត់ និងប្រាំបួនថ្ងៃក្រោយពីពេលចាប់ផ្តើមនៃការហើមនោះ។ ការឆ្លងខ្លាំងបំផុតកើតមានឡើងចាប់ពីពេល 2 ថ្ងៃនៅមុនពេលកើតមានរោគសញ្ញាទាំងឡាយ រហូតដល់ 4 ថ្ងៃក្រោយពីការកើតមានរោគសញ្ញាទាំងនោះ។
- រយៈពេលតាំងពីការប៉ះពាល់វីរុសនេះរហូតដល់មានជំងឺ អាចមានចាប់ពី 12 ទៅ 25 ថ្ងៃ ប៉ុន្តែជាធម្មតាបំផុតគឺពី 16 ទៅ 18 ថ្ងៃ។

## តើអ្នកណាខ្លះដែលអាចមានគ្រោះថ្នាក់កើតជំងឺនេះ?

ជនរាល់រូបដែលប៉ះពាល់សាទ្បាទែនអាចកើតជំងឺសាទ្បាទែនបាន លុះត្រាតែអ្នកទាំងនោះធ្លាប់កើតជំងឺនេះនៅពេលកន្លងមក ឬបានចាក់ថ្នាំបង្ការរោគ។

## តើវិធីបង្ការជំងឺនេះធ្វើឡើងដោយរបៀបណា?

- អ្នកកើតសាទ្បាទែនគួរស្នាក់នៅផ្ទះរយៈពេលប្រាំបួនថ្ងៃ ក្រោយពីការហើមក្រពេញទឹកមាត់ ដើម្បីបញ្ឈប់ការឆ្លងរាលដាលវីរុសនេះទៅកាន់អ្នកដទៃ។
- ថ្នាំបង្ការរោគ MMR ការពារទល់នឹងរោគសាទ្បាទែន  កញ្រ្ជិល និងស្អូច ហើយជាផ្នែកនៃកម្មវិធីចាក់ថ្នាំបង្ការរោគជាស្តង់ដារ។ ថ្នាំបង្ការរោគ MMR គួរចាក់ឲ្យកុមារនៅពេលមានអាយុ 12 ខែ និងម្តងទៀតនៅពេលមានអាយុបួនឆ្នាំ។
- អ្នកមានកំណើតក្រោយពីឆ្នាំ 1965 គួរធ្វើឲ្យប្រាកដថា ខ្លួនបានចាក់ថ្នាំបង្ការរោគ MMR ចំនួនពីរក៏រិត។

## តើការវិនិច្ឆ័យរោគធ្វើទៅតាមរបៀបណា?

ជាធម្មតាវេជ្ជបណ្ឌិតនឹងវិនិច្ឆ័យរោគសាទ្បាទែនដោយផ្អែកតែលើរោគសញ្ញានិងសញ្ញារបស់អ្នកជំងឺប៉ុណ្ណោះ។ តេស្តឈាមឬសំណាកពីបំពង់ក  ទឹកនោម ឬជាតិទឹកនៃខួរឆ្អឹងខ្នងអាចបញ្ជាក់អំពីការកើតមានជំងឺនេះ។

## តើវិធីព្យាបាលជំងឺនេះធ្វើឡើងដោយរបៀបណា?

គ្មានការព្យាបាលជាក់លាក់សំរាប់ជំងឺសាទ្បាទែនទេ។ ថ្នាំបំបាត់ការឈឺចាប់សាមញ្ញអាចកាត់បន្ថយភាពឈឺចាប់និងគ្រុនក្តៅ។ កញ្ចប់ក្តៅឧណ្ហៗឬត្រជាក់ដែលដាក់ពីលើក្រពេញដែលហើម អាចផ្តល់ភាពធូរស្រាលខ្លះ។

## តើផ្នែកសុខភាពសាធារណៈមានវិធានការឆ្លើយតបអ្វីខ្លះ?

- មន្ទីរពិសោធន៍  នាយកសាលារៀន និងនាយកមណ្ឌលថែទាំកុមារ ត្រូវរាយការណ៍ករណីសាទ្បាទែនទាំងអស់ទៅកាន់ផ្នែកសុខភាពសាធារណៈ (Public Health Unit) ក្នុងតំបន់ខ្លួន។ របាយការណ៍ទាំងនេះផ្តល់ស្ថិតិដើម្បីជួយផ្នែកនេះឲ្យយល់អំពីនិន្នាការនៃឧប្បត្តិហេតុរបស់ជំងឺសាទ្បាទែននៅក្នុងសហគមន៍។
- អ្នកកើតសាទ្បាទែនមិនគួរធ្វើដំណើរទៅមណ្ឌលថែទាំកុមារ  សាលារៀន និងកន្លែងធ្វើការ រយៈពេលប្រាំបួនថ្ងៃ ក្រោយពីចេញការហើមក្រពេញទឹកមាត់។

## ព័ត៌មានបន្ថែម – ផ្នែកសុខភាពសាធារណៈ (Public Health) នៅក្នុងរដ្ឋ NSW



**1300 066 055**

**www.health.nsw.gov.au**